ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

## ៣ - សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

### សារាចរស្តីពីការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយនៅពេលប្រឡង

នៅដំណាច់ឆ្នាំសិក្សា ១៩៩៥-៩៦ នេះ នៅទូទាំងប្រទេស និងមានរៀបចំប្រលងបញ្ចប់គ្រប់ ភូមិសិក្សាផ្នែកចំណេះទូទៅ និងបំពេញវិជ្ជាតាមកាលបរិច្ឆេទដូចតទៅ ÷

- ប្រលងវិញ្ញាបនប័ត្របឋមសិក្សា ថ្ងៃទី ១៣ កក្កដា ១៩៩៦
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី១ ថ្ងៃទី ០១ កក្កដា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ លើកទី២ ថ្ងៃទី១៩ សីហា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ លើកទី១ ថ្ងៃទី១០ មិថុនា ១៩៩៦ និងថ្ងៃបន្តបន្ទាប់
- ប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ លើកទី២ ថ្ងៃទី ២២ កក្កដា ១៩៩៦ និងថ្ងៃបន្តបន្ទាប់

កន្លងមកការរៀបចំប្រលង ទទួលបានលទ្ធផលល្អមួយកំរិតធំហើយ ប្រៀបធៀប និង លទ្ធភាពដែលយើងមាន និងសភាពការណ៍ជាក់ស្តែង នៃព្រះរាជាណាចក្រកម្ពុជាយើង តែក៏នៅមាន ចំណុចសេសសល់ខ្លះៗដែលចាំបាច់ត្រូវកែលំអដូចជា :

- ការបង្កភាពអនាធិបតេយ្យរំខានការប្រលង
- ការថតចំលងចំលើយវិញ្ញាសា លក់គគ្រឹកគគ្រេងជុំវិញមណ្ឌលប្រលង
- ចាតុភាពគប់ និងបោះសំដៅចូលបន្ទប់ប្រលង
- ការរត់សំរុកចូល ក្នុងមណ្ឌលប្រលងយកសំណៅអោយបេក្ខជន
- ការគំរាមកំហែងគណៈមេប្រយោគ

អាស្រ័យហេតុនេះ ដើម្បីអោយការប្រលងនៅដំណាច់ឆ្នាំសិក្សា ១៩៩៥-៩៦ នេះប្រព្រឹត្តទៅក្នុងភាពប្រក្រតីមានសណ្តាប់ធ្នាប់រៀបរៀបរយល្អធានាបានភាពយុត្តិធមិ ស្អាតស្អំជូនបេក្ខជន និងមាតា បិតា ឬអាណាព្យាបាលបេក្ខជននោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ÷

១-គ្រប់ក្រសួង និងគ្រប់ខេត្ត-ក្រុងត្រូវចាត់តាំងអប់រំអោយបានទូលំទូលាយជូនមន្ត្រី រាជការ បុគ្គលិក កម្មករ ប្រជារាស្ត្រទូទាំងក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង អោយយល់ពីលក្ខការណ៍នៃការប្រលងដែលផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីចៀសវាងការអនុវត្តនូវប្រការណាមួយផ្ទុយ និងបទបញ្ញត្តិ នៃការប្រលង ឬធ្វើអោយខូចសណ្តាប់ធ្នាប់រៀបរៀបរយ បង្កើតភាពស្មុគ្រស្មាញ ក្នុងពេលប្រលង ។ សូមណែនាំអប់រំបងប្អូន កូនចៅទាំងអស់អោយមានស្មារតីនឹងន និងទុកចិត្តថា រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា នឹងយកចិត្តទុកដាក់ទទួលខុសត្រូវចំពោះការរៀបចំប្រលងអោយបានល្អប្រសើរជូនមាតាបិតា អាណាព្យាបាលសិស្ស និង សិស្សានុសិស្សទាំងអស់ ។ សូមបញ្ឈប់ជាដាច់ខាតនូវការធ្វើអន្តរាគមន៍ និង សូកប៉ាន់គណៈមេប្រយោគ ដើម្បីអោយកូនចៅ ឬកូនក្មួយរបស់ខ្លួនបានប្រលងជាប់ដែលផ្ទុយ នឹងភាពយុត្តិធមិ និងសមត្ថភាពសាមីខ្លួន ។

២-ចំពោះលោកគ្រូ អ្នកគ្រូ ដែលជាគណៈមេប្រយោគ និងមន្ត្រីរាជការដែលមានភារកិច្ចទទួលខុសត្រូវក្នុងការងារប្រលង និង នគរបាល កងអាវុធហត្ថ ដែលមានភារកិច្ចសហការ រក្សាការពារ សណ្តាប់ធ្នាប់ របៀបរៀបរយតាមមណ្ឌលប្រលងនីមួយ ៗ ត្រូវអនុវត្តតាមភារកិច្ចរបស់ខ្លួនអោយបានហ្មត់ចត់ ត្រឹមត្រូវចាំបាច់ធ្វើអោយការងារប្រលងប្រព្រឹត្តទៅក្នុងប្រក្រតីភាព និង ប្រសិទ្ធភាព ចៀសវាង ដាច់ខាតការប្រព្រឹត្តអ្វីដែលធ្វើអោយខូចវិន័យ និងសណ្តាប់ធ្នាប់នៃការប្រលង ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្ដៅបំផុត ចំពោះក្រសួង សាលាខេត្ត ក្រុង ទាំងអស់ថា និង លើកកំពស់ឆន្ទៈអនុវត្តសារាចរណែនាំនេះអោយបានជោគជ័យ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

# III - ការងារបណ្ដាក្រសួង

## ១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៣៥៩ បឈ.ប្រក**

**ស្ដីពីការផ្ទេរនិងតែងតាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល**

- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ដែល ប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ .
- បានឃើញ ប្រកាសលេខ ៧៧៤ ចត.ប្រក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៤ ត្រង់ប្រការ១ ចំណុចទី៣ ស្ដីពីការតែងតាំងលោក ហ៊ុន ប៊ុនថាន